**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**
សំណុំរឿង ព្រហ្មទណ្ឌ
លេខ:០៦
ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០១
**សាលដីកា**
លេខ:០៧
ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៣

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៣ ដោយមានសមាសភាពដូចតទៅ:

១-ឯកឧត្តម ........... ជាប្រធាន
២-លោក ............. ជាចៅក្រម
៣-លោក ............. ជាចៅក្រម
៤-លោក ............... ជាចៅក្រមរបាយការណ៍
៥-លោក ................ ជាចៅក្រម

**ក្រឡាបញ្ជី**

-លោក ......................។

**តំណាងមហាអយ្យការ**

-លោក ............. ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីកាព្រហ្មទណ្ឌលេខ១៧៨ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ និងសំណុំរឿងព្រហ្មទណ្ឌលេខ៦ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ ២១របស់តុលាការកំពូល ។

**ពីបទ** : បើកបររថយន្តធ្វើឲ្យអ្នកដទៃមានគ្រោះថ្នាក់ដល់ស្លាប់ ប្រព្រឹត្តនៅភូមិធ្នល់ឃុំចេក ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង កាលពីថ្ងៃទី១១-០៥-១៩៩៨ វេលាម៉ោង៥.៤០ល្ងាច ។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមមាត្រា៦០ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ។

-ជនជាប់ចោទឈ្មោះ នចថ ភេទប្រុស អាយុ៣៨ឆ្នាំ ជាតិខ្មែរ របររកស៊ីបើកបររថយន្ត ទីលំនៅសព្វថ្ងៃភូមិបន្ទាយ ឃុំកណ្តៀងរាយ ស្រុកស្វាយទាប ខេត្តស្វាយរៀង ឪពុកឈ្មោះប៉ោ ឡាច (ស) ម្តាយឈ្មោះឡុង ណាន (រ) ប្រពន្ធឈ្មោះកែ មុត ហៅង៉ែត មានកូន០៣នាក់ក្រៅឃុំ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ វចថ (ជាចុងបណ្តឹងសាទុក្ខ) ភេទស្រី អាយុ៣៩ឆ្នាំ ជាតិខ្មែរ របររកស៊ីធ្វើស្រែ ទីលំនៅសព្វថ្ងៃភូមិចំបក់ ឃុំរំចេក ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង ។

-អ្នកទទួលខុសត្រូវរដ្ឋប្បវេណីឈ្មោះ ឈម ផ្ទេរសិទ្ធិឲ្យឈ្មោះ ករវ (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៣៧ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃភូមិស្វាយក្ងោក ឃុំស្វាយជ្រុំ ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង ។

-កាលពីថ្ងៃទី១១ខែឧសភា ឆ្នាំ១៩៩៨ វេលាម៉ោង១៧.៤០នាទីល្ងាច ឈ្មោះនចថ បានបើករថយន្តឈ្នួល ម៉ាកនីសាន់ផ្លាកលេខ០៦៧ភ៣២ ពណ៌ប្រផេះ បើកចេញពីស្វាយរៀងឆ្ពោះ ទៅឃុំក្រោលគោ តាមផ្លូវជាតិលេខ១ លុះដល់ត្រង់ចំណុចតារាងយន្តហោះទល់មុខការដ្ឋានសំណង់ យូណាតនៅក្នុងភូមិធ្នល់ ឃុំចេក ស្រុកស្វាយជ្រំ ស្រាប់តែរថយន្តនេះផ្អៀងចង្កូតទៅបុកឈ្មោះសុផាត ដែលកំពុងជិះម៉ូតូលើផ្លូវថ្នល់ពីលិចទៅកើតបញ្ច្រាស់ទិសគ្នាខាងឆ្វេងនៃរថយន្ត បណ្តាលឲ្យឈ្មោះ នេះស្លាប់នៅនឹងកន្លែងមួយរំពេច ។ ក្នុងពេលនោះឈ្មោះនចថ ក៏បានបើកម៉ាស៊ីនលាយស៊ីម៉ង់

ត៍ រួចក្រឡាប់នៅទីនោះទៅ ចំណែកឈ្មោះនចថ ក៏រត់គេចខ្លួនបាត់ចាប់តាំងពីពេលនោះមក ចៅក្រមស៊ើបអង្កេតបាន ចេញដីកាចាប់ខ្លួនលេខ៤៤ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ១៩៩៨ រួចហើយដែរ ។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ អមតុលាការខេត្តស្វាយរៀងថា៖ ចោទប្រកាន់លើឈ្មោះ នចថ អាយុ៣៨ឆ្នាំ ភេទប្រុស ជាតិខ្មែរ របររកស៊ីធ្វើស្រែ និងស៊ីឈ្នួលបើករថយន្ត ទីលំនៅភូមិបន្ទាយ ឃុំកណ្តៀងរាយ ស្រុកស្វាយទាប ខេត្តស្វាយរៀង។ ឪពុកឈ្មោះប៉ោ ឡាច (ស) ម្តាយមិនស្គាល់ឈ្មោះ ប្រពន្ធឈ្មោះកែ យ៉ុត មានកូន ០៣នាក់ ទោសពីមុនគ្មាន ។ **ពីបទ** បើកបរធ្វើឲ្យអ្នកដទៃមានគ្រោះថ្នាក់ ប្រព្រឹត្តនៅភូមិធ្នល់ ឃុំចេក ស្រុកស្វាយជ្រ ខេត្តស្វាយរៀង កាលពីថ្ងៃទី១១ ខែឧសភា ឆ្នាំ១៩៩៨ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោស តាមមាត្រា៦០ នៃច្បាប់ ស្តីពីចរាចរណ៍ផ្លូវគោក ។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ៤៥ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ១៩៩៨ របស់តុលាការ ខេត្តស្វាយរៀង ដែលបានសម្រេច

១-ផ្តន្ទាទោសកំបាំងមុខឈ្មោះនចថ ដាក់ពន្ធនាគារកំណត់០៣ឆ្នាំ គិតចាប់ពី ថ្ងៃចាប់ឃុំខ្លួនពីបទ បើកបររថយន្តខុសច្បាប់ចរាចរណ៍ បណ្តាលឲ្យមានគ្រោះថ្នាក់ដល់អ្នកដទៃ(ស្លាប់) ប្រព្រឹត្តនៅភូមិធ្នល់ ឃុំចេក ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង កាលពីថ្ងៃទី១១ ខែឧសភា ឆ្នាំ១៩៩៨ វេលាម៉ោង៥.៤០នាទីល្ងាច បទល្មើសព្រហ្មទណ្ឌ ដែលមានចែង និងផ្តន្ទាទោសតាមមាត្រា៦០ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ។

២-ឲ្យឈ្មោះឈម ម្ចាស់រថយន្តសងសំណងជម្ងឺចិត្ត និងការចំណាយធ្វើបុណ្យទានសព ព្រមទាំងសងថ្លៃម៉ូតូចំនួន១គ្រឿង ទៅឲ្យឈ្មោះនារី វចថ ដើមបណ្តឹងរដ្ឋប្បវេណី ជាប្រាក់សរុបទាំងអស់ចំនួន ៧០០០០០០ រៀល ប្រាំពីរលានរៀល ។ សំណើលើសពីនេះត្រូវលើកចោល តាមមាត្រា១២៥ នៃក្រិត្យច្បាប់លេខ៣៨ក្រ.ច ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៨៨ ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា ។ ក្នុងប្រាក់ចំនួន៧.០០០០០០ រៀលនេះត្រូវដកចំនួន ៨០០០០០រៀល សំរាប់សងទៅម្ចាស់ម៉ូតូឈ្មោះកឹម សាខន ។

៣-វត្ថុតាងមានរថយន្តនីសាន់ពណ៌ប្រផេះចំនួន០១គ្រឿង ពាក់ផ្លាកលេខ០០៦៧ ភព២ តួលេខ០៦៧៧៣ លេខម៉ាស៊ីន០៨២៥១៣ ត្រូវរឹបអូសទុកជានាសំណងខាងលើ ។

ឯចំណែកម៉ូតូធុន១២៥ ចំនួន១គ្រឿង ដែលរងគ្រោះនខ្ទិចខ្ទីនោះ ត្រូវដកហូតរួចប្រគល់ទៅឲ្យម្ចាស់កម្មសិទ្ធិវិញ ។

៤-សាលក្រមនេះជំនុំជំរះ និងប្រកាសជាសាធារណៈកំបាំងមុខឈ្មោះនចថ និងឈ្មោះឈម ម្ចាស់រថយន្ត ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះនារី វចថ ។

-បើកសិទ្ធិប្តឹងទាស់រយៈពេល១៥ថ្ងៃ គិតពីថ្ងៃទទួលដំណឹង

-បើកផ្លូវប្តឹងឧទ្ធរណ៍រយៈពេល២ខែ គិតពីថ្ងៃនេះតទៅ ។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ០៨ ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ១៩៩៨ របស់ឈ្មោះឈម ដែលប្តឹងមិនសុខចិត្ត ពីសាលក្រមព្រហ្មទណ្ឌលេខ៤៥ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ១៩៩៨ របស់តុលាការខេត្តស្វាយរៀង លើចំណុចទី២នៃ សេចក្តីសម្រេច ។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមសាលាឧទ្ធរណ៍ថា ៖

១-ទទួលបណ្តឹងឧទ្ធរណ៍របស់ឈ្មោះឈម ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ១៩៩៨ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ។

២-តម្កល់សាលដីកាលេខ៤៥ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ១៩៩៨ របស់តុលាការ ខេត្តស្វាយរៀង ទុកជាបានការទាំងមូល ។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ១៧៨ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេច

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ១៩៩៨ របស់ឈ្មោះឈម ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-តម្កល់សាលាក្រមព្រហ្មទណ្ឌលេខ៤៥ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ១៩៩៨ របស់តុលាការខេត្តស្វាយរៀងទុកជាបានការដដែល ។

៣-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីកំបាំងមុខជនជាប់ចោទប្រើកផ្លូវប្តឹងតវ៉ាតាមកំណត់ច្បាប់ ។

-បានឃើញបណ្តឹងសាទុក្ខលេខ៧៩ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០០ របស់ឈ្មោះកវប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ១៧៨ចុះថ្ងៃទី២១ខែកក្កដា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ លើសេចក្តីសម្រេចទាំងមូល ។

-បានឃើញសារណា ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ របស់ឈ្មោះកៅ វិរៈ (ជាម្ចាស់បណ្តឹងសាទុក្ខ) ធ្វើឡើងក្នុងកំណត់ច្បាប់ ។

-បានឃើញសារណាតប ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០១ របស់ឈ្មោះវចថ (ជាចុងបណ្តឹងសាទុក្ខ) ធ្វើឡើងក្នុងកំណត់ច្បាប់ ។

-បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមតុលាការកំពូលថាៈ ជនជាប់ចោទឈ្មោះនចថ ពិតជាបើកបរបណ្តាលឲ្យជនរងគ្រោះស្លាប់ សូមតម្កល់សាលដីកាសាលាឧទ្ធរណ៍ ទុកជាបានការ ។

-បានស្តាប់ចម្លើយអះអាងរបស់ឈ្មោះកវរ(ជាម្ចាស់បណ្តឹងសាទុក្ខ) នៅពេលជំនុំជំរះថាៈ ខ្ញុំមានតែមួយចំណុចទេ សូមក្រុមប្រឹក្សាជំនុំជំរះបន្ថយសំណាងឲ្យខ្ញុំបាទ ដោយក្តីអនុគ្រោះ ។

-បានស្តាប់អំណានសារណាតប របស់ឈ្មោះវចថ (ជាចុងបណ្តឹងសាទុក្ខ) នៅពេលជំនុំជំរះ។

-បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែម របស់តំណាងមហាអយ្យការអមតុលាការកំពូលថាៈ សូមតម្កល់សេចក្តីសន្និដ្ឋានខាងលើទុកនៅដដែល ។

-ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយដោនសាររបស់លោកកវរនិងសារណារបស់ដើមបណ្តឹងរដ្ឋប្បវេណី ។

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ ។

## តុលាការកំពូ

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ៧៩ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០០ របស់ឈ្មោះកវរតំណាងឱ្យអ្នកទទួលខុសត្រូវសំណងរដ្ឋប្បវេណីឈ្មោះឈម ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថា មានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថាឈ្មោះនចថ ពិតជាបានប្រព្រឹត្តិ បទល្មើសដោយបើកបររថយន្តធ្វើឱ្យអ្នកដទៃមានគ្រោះថ្នាក់ដល់ស្លាប់ ប្រព្រឹត្តិនៅភូមិធ្នល់ ឃុំចេក ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង កាលពីថ្ងៃទី១១ ខែឧសភា ឆ្នាំ១៩៩៨ វេលាម៉ោង៥ះ៤០នាទី បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោលតាមមាត្រា៦០ នៃច្បាប់ស្តីពីចរាចរផ្លូវគោក ។

-យល់ឃើញថា រថយន្តដែលឈ្មោះនចថ បើកបរនេះជាកម្មសិទ្ធិរបស់លោកឈម ដែលតាមមាត្រា១២៦ នៃក្រឹត្យច្បាប់ស្តីពីកិច្ចសន្យា និ ការទទួលខុសត្រូវក្រៅតិច្ចសន្យាលោកឈម ត្រូវទទួលខុសត្រូវលើសំណងអំពីព្យសនកម្មដែលបង្កឡើងដោយនិយោជិករបស់ខ្លួន ។

-យល់ឃើញថា ការដែលតំណាងឱ្យលោកឈម លើកឡើងអំពីសំណងលើព្យសនកម្មនោះ តុលាការកំពូលពុំអាចពិចារណាបានឡើយ ។

-យល់ឃើញថា ដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើសារណាការពាររឿងក្តីរបស់ខ្លួន ជូនមកតុលាការកំពូលរួចហើយ ប៉ុន្តែពុំបានមកចូលរួមសវនាការនេះទេ ដូច្នេះទតុលាការកំពូលជំនុំជំរះរឿង នេះកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ១៧៨ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ដែលបានសម្រេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវទាំងទម្រង់ ទាំងគតិច្បាប់ហើយ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសមន្និចំពោះមុខអ្នកទទួលខុសត្រូវសំណាង ខ្ទច្ចប្បវេណីកំចាំងមុនទើបបង្តើនៃអច្ចប្បវេណី ប៉ុន្តែមាត់មុចចាំម៉េចព្រះមុខ**

១- ទទួលបណ្តឹងសាទុក្ខលេខ៧៩ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០០ របស់ឈ្មោះកវទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២- តម្កល់សាលដីកាព្រហ្មទណ្ឌលេខ១៧៨ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣- សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៣ ។